

# រត់ប្រណាំង

Let's Read
The Asia Foundation



ថ្ងៃមួយ ទន្សាយបានឃើញខ្យងមួយកំពុងវារ។ ទន្សាយបាននិយាយទៅកាន់ខ្យងថា «ឯងរត់មិនលឿនទេ! ឯងចេះតែវារគើមៗលើដីប៉ុណ្ណោះ។»




ខ្យងក៏និយាយទៅវិញ «មក មកជួបខ្ញុំនៅថ្ងៃអាទិត្យមក!»។



ខ្យងបានរៀបចំក្រដាសរាប់រយសន្លឹក និងសរសេរពាក្យដដែលៗ នៅលើក្រដាសទាំងនោះ។



ខ្យងបានឱ្យក្រដាសទាំងនោះទៅមិត្តភក្តិរបស់វា ហើយនិយាយថា «នៅពេលដែលទន្សាយមកហៅខ្ញុំនៅទីនេះ សុំឱ្យគ្នាយើងម្នាក់និយាយថា ខ្ញុំគឺជាខ្យង»។



បន្ទាប់មក ខ្យងបានប្រាប់មិត្តរបស់វាឱ្យលាក់ខ្លួននៅក្រោយ
គុម្ពោតព្រៃនៅកន្លែងដែលទន្សាយ និងខ្យងត្រូវឆ្លងកាត់។



នៅថ្ងៃអាទិត្យ ទន្សាយបានមកដល់ហើយឃើញខ្យងនោះ។ ទន្សាយបាននិយាយថា «តោះរត់ប្រណាំងគ្នា ប៉ុន្តែខ្ញុំនឹងឈ្នះ!»។




ខ្យងបានតម្រៀបគ្នានៅក្រោយដើមឈើតាមផ្លូវដែលត្រូវ ប្រណាំងគ្នា ហើយរាល់ពេលដែលទន្សាយឆ្លងកាត់ ខ្យងមួយ នឹងស្រែកថា «ខ្ញុំគឺជាខ្យង...»។ នៅពេលប្រណាំង ទន្សាយបាន ហៅឮៗថា «ខ្យងអើយ ខ្យង!»។




ខ្យងមួយលាក់ខ្លួននៅក្រោយគុម្ពោតព្រៃបានឆ្លើយថា «ខ្ញុំគឺជាខ្យង! ខ្ញុំគឺជាខ្យង!»។




ជាចុងក្រោយ ទន្សាយក៏អស់កម្លាំង។ វាក៏បានដេកដាក់ខ្លួន
លើដី ហើយនិយាយថា «ខ្យងអើយ ខ្ញុំហត់ណាស់។ ឯង
ឈ្នះហើយ។» ខ្យងមួយបានមើលមកពីក្រោយគុម្ពោតព្រៃ។




ដូចនេះហើយ ខ្យងក៏បានឈ្នះការប្រកួត ដោយសារភាពឈ្លាសវៃរបស់ខ្លួន។

Brought to you by

The Asia Foundation

Let's Read is an initiative of The Asia Foundation's Books for Asia program that fosters young readers in Asia and the Pacific.
booksforasia.org
To read more books like this and get further information about this book, visit letsreadasia.org

**Original Story**
*The Race*, Published by African StoryBook, © African StoryBook. Released under CC BY 3.0.

This work is a modified version of the original story. © The Asia Foundation, 2018. Some rights reserved. Released under CC BY 3.0.

For full terms of use and attribution, http://creativecommons.org/licenses/by/3.0/
Contributing translators: SOEURM Kakada, Sodany Ouch, and Ly Chanmakara